**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៤៤៥ ព.ណ.កសប

ថ្ងៃ ពុធ ៧រោច ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ក្រសួងនឹងរៀបចំការប្រកួតប្រជែងវីដេអូយុវជនក្នុងទិវាកម្មសិទ្ធិបញ្ញាពិភពលោកឆ្នាំ២០២២ ក្រោមប្រធានបទ "**កម្មសិទ្ធិបញ្ញានិងយុវជន៖ការបង្កើតថ្មីសម្រាប់អនាគតកាន់តែប្រសើរ**" ដែលមានលក្ខខណ្ឌដូចខាងក្រោម៖

## ក. មូលបទវីដេអូ

ប្រធានបទវីដេអូផ្តោតទៅលើ៖ *"ពួកយើងជាយុវជននិងមានគំនិតបង្កើតថ្មី" ចាប់ផ្តើមពីពេលឥឡូវនេះ ពួកយើងនាំគ្នាកសាងអនាគតឱ្យកាន់តែល្អប្រសើរជាមួយកម្មសិទ្ធិបញ្ញា!*

- ការថតវីដេអូរបស់អ្នកគួរផ្តោតទៅលើការជ្រើសរើសមាតិការបស់អ្នក ហើយត្រូវបង្ហាញអំពីដំណោះស្រាយដែលប្រកបដោយការបង្កើតថ្មី និងគាំទ្រដោយកម្មសិទ្ធិបញ្ញា ដែលផ្តល់ការដោះស្រាយបញ្ហាប្រឈមទៅនឹងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះយុវជន ឧទាហរណ៍ដូចជា៖ បម្រែបម្រួលអាកាសធាតុ សុខភាពសកល ការរស់នៅប្រកបដោយនិរន្តរភាព ការផ្តល់អំណាចដល់យុវជន។
- វីដេអូពន្យល់ពីកម្លាំងកម្មសិទ្ធិបញ្ញា អនុវត្តបានក្នុងការកសាងអនាគតដ៏ល្អប្រសើរនឹងត្រូវបានវាយតម្លៃដោយភាពអនុគ្រោះពីគណកម្មាធិការវិនិច្ឆ័យ។

## ខ. សិទ្ធិចូលរួមប្រកួត

លក្ខណវិនិច្ឆ័យសម្រាប់ការប្រកួត៖

- អ្នកដាក់ពាក្យចូលរួមត្រូវមានអាយុចាប់ពី១៨ ដល់៣៥ឆ្នាំ គិតត្រឹមថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ (កាលបរិច្ឆេទបិទការចុះឈ្មោះសម្រាប់កម្មវិធីប្រកួតប្រជែងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO)) អ្នកចូលរួមអាចតម្រូវឱ្យផ្តល់ឯកសារផ្លូវការដើម្បីបញ្ជាក់ពីអាយុតាមការស្នើសុំ។
- រាល់ការចូលរួមទាំងអស់ត្រូវតែផ្ញើវីដេអូរបស់ខ្លួនជូនអង្គការWIPO ត្រឹមថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ម៉ោង២៣:៥៩(ម៉ោងសហភាពអឺរ៉ុប) ត្រូវនឹងម៉ោង៥:៥៩នាទីព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ម៉ោងនៅកម្ពុជា សម្រាប់កម្មវិធីប្រកួតប្រជែងរបស់អង្គការ WIPO ។
- សម្រាប់មូលបទវីដេអូដូចគ្នា អ្នកដាក់ពាក្យអាចចូលរួមកម្មវិធីប្រកួតប្រជែងថ្នាក់ជាតិផងដែរ ហើយត្រូវផ្ញើវីដេអូមកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មឱ្យបានមុនថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ម៉ោង១៧:00 ។
- អ្នកចូលរួមអាចជាបុគ្គល ឬចូលរួមជាមួយមិត្តភក្តិ ហើយផ្ញើជូនការចូលរួមជាក្រុម។ ការចូលរួមអាចធ្វើឡើងបានតែម្តងគត់សម្រាប់ការចូលរួមជាបុគ្គល ឬជាក្រុម។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- បុគ្គលិក ឬភ្នាក់ងារអង្គការWIPO សមាជិកគ្រួសារជិតស្និទ និងបុគ្គលជាប់ពាក់ព័ន្ធជាមួយអង្គការនៃការប្រកួតប្រជែងមិនអាចចូលរួមបានទេ។
- ប្រសិនបើអ្នកចូលរួមមិនអនុលោមតាមលក្ខណវិនិច្ឆ័យទាំងនេះទេ សិទ្ធិចូលរួមនឹងបានត្រូវដកចេញ។

## គ. លក្ខខណ្ឌនៃការចូលរួម

បន្ថែមលើលក្ខណវិនិច្ឆ័យសម្រាប់ការចូលរួមប្រកួត អ្នកដាក់ពាក្យចូលរួមត្រូវតែបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- វីដេអូត្រូវតែទាក់ទងនឹងមូលបទ **"ពួកយើងជាយុវជននិងមានគំនិតបង្កើតថ្មី" ចាប់ផ្តើមពីពេលឥឡូវនេះ ពួកយើងនាំគ្នាកសាងអនាគតឱ្យកាន់តែល្អប្រសើរជាមួយកម្មសិទ្ធិបញ្ញា!** និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖
  - វីដេអូមិនត្រូវបានគេស្គាល់ជាសាធារណៈពីមុន ឬធ្លាប់ទទួលពានរង្វាន់ពីការប្រកួតប្រជែងណាមួយ។
  - វីដេអូសម្រាប់ការដាក់ពាក្យចូលរួម ត្រូវបង្កើតឡើងនិងនិពន្ធដោយអ្នក ឬក្រុមរបស់អ្នក។
  - អ្នក ឬក្រុមរបស់អ្នក មានសិទ្ធិទាំងស្រុងលើវីដេអូ ហើយក្នុងករណីប្រើប្រាស់មាតិការបស់ភាគីទីបីដើម្បីបញ្ចូលក្នុងវីដេអូនេះ ត្រូវមានការអនុញ្ញាតពីម្ចាស់សិទ្ធិជាមុនសិន ។ វីដេអូរបស់អ្នក មិនត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញពីមុនមកទេ។
  - វីដេអូរបស់អ្នកមិនត្រូវបញ្ចូល watermarks ឬ សញ្ញាសម្គាល់ស្រដៀងដទៃទៀតនោះទេ។
  - វីដេអូរបស់អ្នកត្រូវធ្វើឡើងតាមទម្រង់ MP4 ហើយមានរយៈពេលចន្លោះពី៣០ ទៅ៩០ វិនាទី។
  - វីដេអូអាចមានសម្លេងពោលជាភាសាណាមួយដូចជា៖ អារ៉ាប់ ចិន អង់គ្លេស បារាំង ជប៉ុន ព័រទុយហ្គាល់ រុស្ស៊ី ឬអេស្ប៉ាញ។
  - វីដេអូមានសម្លេងពោល ត្រូវភ្ជាប់មកជាមួយអត្ថបទជាអក្សរនៅខាងក្រោមវីដេអូ។
  - វីដេអូដាក់ពាក្យចូលរួមក្នុងកម្មវិធីប្រកួតប្រជែងថ្នាក់ជាតិ មិនត្រូវបានចាត់ទុកថាគេស្គាល់ជាសាធារណៈ ដែលផ្ទុយនឹងលក្ខខណ្ឌខាងលើទេ។
- **<u>សម្រាប់កម្មវិធីប្រកួតប្រជែងរបស់អង្គការWIPO</u>** អ្នកដាក់ពាក្យត្រូវផ្ញើវីដេអូចូលរួមលើថ្នាលប្រកួតប្រជែងដោយបំពេញឯកសារតម្រូវទាំងអស់លើទម្រង់ការដាក់ពាក្យ និងដាក់បញ្ចូលឯកសារនានាតាមការចង្អុលបង្ហាញនៅលើថ្នាល https://wipd2022-prize.wipo.int។
- **<u>សម្រាប់កម្មវិធីប្រកួតប្រជែងថ្នាក់ជាតិ</u>** អ្នកដាក់ពាក្យត្រូវផ្ញើវីដេអូចូលរួមនិងឯកសារតម្រូវតាមប្រព័ន្ធតេឡេក្រាមមានទូរស័ព្ទលេខ **០១២ ២៦១ ៥៣៦**។

## ឃ. ដំណើរការចូលរួមនិងបោះឆ្នោត

- អង្គការWIPO/នាយកដ្ឋានកម្មសិទ្ធិបញ្ញា នឹងត្រួតពិនិត្យលើការដាក់ពាក្យចូលរួមដើម្បីធានាថា ការចូលរួមនោះអនុលោមតាមវិធាននៃលក្ខណៈសម្បត្តិ។
- សេចក្តីសម្រេចរបស់អង្គការWIPO/នាយកដ្ឋានកម្មសិទ្ធិបញ្ញា ទាក់ទងទៅនឹងសិទ្ធិនៃការចូលរួមគឺជាការសម្រេចចុងក្រោយ។
- អង្គការWIPO/នាយកដ្ឋានកម្មសិទ្ធិបញ្ញា អាចសម្រេចចិត្តដកចេញដោយពុំចាំបាច់ជូនដំណឹងជាមុន រាល់ការចូលរួមប្រកួតប្រជែង ប្រសិនបើការចូលរួមពុំបានអនុលោមតាមវិធាននៃលក្ខណៈសម្បត្តិខាងលើ។
- វីដេអូដែលមានខ្លឹមសាររំលោភបំពាន គំរាមកំហែង ភូតកុហក ធ្វើឱ្យមានការភាន់ច្រឡំ បៀតបៀនកេរ្តិ៍ខ្មាស ជេរប្រមាថ បង្ខូចកេរ្តិ៍ឈ្មោះ សញ្ញាមិនល្អ អសីលធម៌ រឿងអាស្រូវ អំពើហិង្សា រឿងអាសអាភាស នឹងត្រូវបដិសេធការដាក់ពាក្យចូលរួម។
- វីដេអូដាក់ពាក្យចូលរួមនឹងត្រូវវិនិច្ឆ័យដោយអង្គការWIPO តាមរយៈក្រុមការងារទិវាកម្មសិទ្ធិបញ្ញាពិភពលោក និង

វីដេអូនឹងត្រូវវិនិច្ឆ័យលើការប្រកាន់ភ្ជាប់ទៅនឹងមូលបទរបស់ពួកគេ ការបង្ហាញពីប្រធានបទ ប្រភពដើម ការច្នៃប្រឌិត និងភាពទាក់ទាញ ដែលមើលឃើញក្នុងចំណោមអ្នកដទៃ។

- អ្នកចូលរួមដែលបានជ្រើសរើសក្នុងបញ្ជីឈ្មោះសម្រិតសម្រាំងនឹងត្រូវជូនដំណឹងតាមរយៈសារអេឡិចត្រូនិក។
- សេចក្តីសម្រេចរបស់អង្គការ WIPO ទាក់ទងនឹងវីដេអូដែលត្រូវបានជ្រើសរើសក្នុងបញ្ជីសំម្រិតសម្រាំង គឺជាការសម្រេចចុងក្រោយ។
- វីដេអូដែលបានជ្រើសរើសក្នុងបញ្ជីសម្រិតសម្រាំង នឹងត្រូវផ្សព្វផ្សាយដោយអង្គការWIPO លើថ្នាលប្រកួតប្រជែង និងត្រូវផ្សព្វផ្សាយលើថ្នាលសំខាន់ៗផ្សេងៗទៀត។
- អ្នកចូលរួមដែលបានជ្រើសរើសក្នុងបញ្ជីសម្រិតសម្រាំង អាចត្រូវបានស្នើឱ្យបង្ហោះវីដេអូរបស់ពួកគេលើថ្នាលប្រព័ន្ធផ្សព្វផ្សាយសង្គមដោយការប្រើ #WIPD, #IP&Youth, #WIPDYouthVideos ។
- វីដេអូសម្រិតសម្រាំងទាំងអស់នឹងត្រូវបោះឆ្នោតជាសាធារណៈលើថ្នាលប្រកួតប្រជែងដើម្បីកំណត់វីដេអូកំពូលចំនួន១០( https://wipd2022-prize.wipo.int )។
- អ្នកចូលរួមទាំង១០ដែលទទួលបានការបោះឆ្នោតវីដេអូល្អបំផុតនឹងក្លាយជាអ្នកឈ្នះក្នុងការប្រកួតប្រជែងនេះ។ អ្នកឈ្នះនឹងត្រូវប្រកាសលើគេហទំព័រ World Intellectual Property Day និងថ្នាលប្រកួតប្រជែង ហើយនឹងត្រូវផ្សព្វផ្សាយលើថ្នាលសំខាន់ៗផ្សេងៗទៀត។
- **សម្រាប់ការចូលរួមកម្មវិធីប្រកួតប្រជែងថ្នាក់ជាតិ** អាចអនុវត្តលក្ខខណ្ឌខាងលើនេះផងដែរ។

## ខ. ពានរង្វាន់

### ១. សម្រាប់កម្មវិធីប្រកួតប្រជែងរបស់អង្គការ WIPO អ្នកឈ្នះនឹងទទួលបានរង្វាន់ដូចខាងក្រោម៖

- រង្វាន់ទី១៖ ឧបករណ៍ឌីជីថលតម្លៃអតិបរិមា ៥០០០ ស្វីសហ្វ្រង់ (ឬតម្លៃសមមូលរូបិយប័ណ្ណផ្សេង)
- រង្វាន់ទី២៖ ឧបករណ៍ឌីជីថលតម្លៃអតិបរិមា ៣០០០ ស្វីសហ្វ្រង់ (ឬតម្លៃសមមូលរូបិយប័ណ្ណផ្សេង)
- រង្វាន់ទី៣៖ ឧបករណ៍ឌីជីថលតម្លៃអតិបរិមា ១០០០ ស្វីសហ្វ្រង់ (ឬតម្លៃសមមូលរូបិយប័ណ្ណផ្សេង)

- អង្គការWIPO នឹងទិញជំនួសឧបករណ៍ឌីជីថល ដែលជ្រើសរើសដោយអ្នកឈ្នះទាំងបីនាក់។
- វីដេអូដែលល្អបំផុតទាំង១០នឹងទទួលបានអត្ថប្រយោជន៍ពីការផ្តល់ឱកាសចូលរួមបណ្តុះបណ្តាលដែលផ្តល់ដោយបណ្ឌិត្យសភាអង្គការកម្មសិទ្ធិបញ្ញា( https://www.wipo.int/academy/en/ )។
- ព័ត៌មានលម្អិតពីរង្វាន់ទាំងនេះ នឹងត្រូវប្រកាសនៅពេលអ្នកឈ្នះវគ្គសម្រិតសម្រាំងត្រូវបានប្រកាសផ្សព្វផ្សាយ។

**២. សម្រាប់កម្មវិធីប្រកួតប្រជែងថ្នាក់ជាតិ** អ្នកទទួលជ័យលាភីនឹងប្រកាសថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ក្នុងទិវាកម្មសិទ្ធិបញ្ញាពិភពលោក។

សម្រាប់បេក្ខជនដែលមានចំណាប់អារម្មណ៍អំពីការប្រកួតប្រជែងខាងលើនេះ អាចទំនាក់ទំនងផ្ទាល់មកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម រៀងរាល់ម៉ោងធ្វើការ ឬទំនាក់ទំនងទូរស័ព្ទលេខ ០៩៥ ៣៣៣ ២៣១ និង០៨១ ៥៦៧ ៥៦៧។ សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម